ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន
អង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុ
លេខ: ...៣២៣............/អ.រ.ហ

រាជធានីភ្នំពេញ, ថ្ងៃទី..១៥. ខែ...ធ្នូ...... ឆ្នាំ២០១៦.

**គោរពជូន**

**ឯកឧត្តមប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**កម្មវត្ថុ** : ការរៀបចំបិទបញ្ជីគណនេយ្យប្រចាំឆ្នាំ២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមជម្រាបឯកឧត្តមមេត្តាជ្រាបថា លេខាធិការដ្ឋាន គ.ជ.អ.ប នឹងរៀបចំបូកសរុបរបាយការណ៍ហិរញ្ញវត្ថុនៃការអនុវត្តផែនការថវិកាឆ្នាំ២០១៦ នាដំណាច់ឆ្នាំ២០១៦ ខាងមុខនេះ។ ដើម្បីសម្របសម្រួល និងជំរុញដល់ការបិទបញ្ជីថវិកាឆ្នាំ២០១៦ សម្រាប់លេខាធិការដ្ឋាន គ.ជ.អ.ប អង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុ ស្នើសុំការឯកភាពពីឯកឧត្តមលើគោលការណ៍មួយចំនួន ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានការចុះបេសកកម្មទៅតាមបណ្តាខេត្តនានា ចាប់ពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ លើកលែងករណីដែលឯកឧត្តមប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប កំណត់ថាជាករណីចាំបាច់បំផុត និងមានការឯកភាពជាមុនពីថ្នាក់ដឹកនាំលេខាធិការដ្ឋាន គ.ជ.អ.ប

២. មិនអនុញ្ញាតឱ្យមានការអនុវត្តសកម្មភាពនានាចាប់ពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ លើកលែងករណីដែលឯកឧត្តមប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប កំណត់ថាជាករណីចាំបាច់បំផុត និងមានការឯកភាពជាមុនពីថ្នាក់ដឹកនាំលេខាធិការដ្ឋាន គ.ជ.អ.ប

៣. អង្គភាពទាំងអស់ត្រូវប្រមូលសំណុំឯកសារបេសកកម្មដែលបានបញ្ចប់ មកអង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីស្នើសុំការទូទាត់ ត្រឹមថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦

៤. អង្គភាពទាំងអស់ត្រូវប្រមូលសំណុំឯកសារជម្រះបញ្ជីថវិកាបុរេប្រទាន ចំពោះសកម្មភាពក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ ដែលបានអនុវត្តរួចរាល់ មកអង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុ ត្រឹមថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ ដើម្បីរៀបចំការជម្រះថវិកា។

ករណីមានសកម្មភាពសំខាន់ និងចាំបាច់ត្រូវការអនុវត្តនៅកំឡុងចុងឆ្នាំ២០១៦នេះ ត្រូវមានការពិភាក្សាជាមួយអង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីត្រៀមបញ្ចូលចំណាយសម្រាប់បិទបញ្ជី។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ប្រធានអង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុ**

**ស៊ី ថារិន**

15/12/16